9947
3/3

# សាមណេរវិន័យ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

www.elibraryofcambodia.org

ភ្នំពេញ

ព. ស. ២៥១៦

J S R C K I D FEBRUARY 1990

17 JUN 1997

www.elibraryofcambodia.org

# សារម្ភកថា

គណៈកម្មាធិការ ពុទ្ធិកសមាគមកម្ពុជរដ្ឋ ជំរំសម្តេចឪ និងព្រះគ្រូចៅអធិការ វត្តសម្តេចឪ ជំរំសម្តេចឪ យល់ឃើញថា សៀវភៅ សាមណេរវិន័យនេះ មានសារៈសំខាន់ដល់បព្វជិតភេទ ទូទៅក្នុងព្រះពុទ្ធសាសនា ទើបស្របមតិគ្នា ស្នើសុំអង្គការ ---- J S RC ------ តាមរយៈរដ្ឋបាល ជំរំសម្តេចឪ ឱ្យជួយ បោះពុម្ពសារជាថ្មី ដើម្បីផ្សាយជាធម្មទាន ។

ធ្វើនៅថ្ងៃទី ១៣ មករា ព.ស ២៥៣៣

www.elibraryofcambodia.org

គណៈកម្មាធិការ ពុទ្ធិកសមាគមកម្ពុជរដ្ឋ ជំរំសម្តេចឪ

ឧបត្ថម្ភដោយអង្គការ ---- J SRC --------

9947
3/3
17 JUN 1997

www.elibraryofcambodia.org

ព្រះគ្រូសង្ឃសត្ថា ជួន-ណាត អាចារ្យបង្រៀនសាលាបាលីជាន់ខ្ពស់

ព្រះគ្រូសង្ឃវិជ្ជា ហួត-តាត អាចារ្យបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់

និង

ព្រះគ្រូវិមលបញ្ញា អ៊ុំ-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យ

# រៀបរៀង

គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈបានអនុញ្ញាតហើយ

បោះពុម្ពលើកទី ១៤

ចំនួន ១០.០០០ ច្បាប់

www.elibraryofcambodia.org

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៤

www.elibraryofcambodia.org

# បញ្ជីរឿង


| មាតិកា រឿង | ទំព័រ |
|---|---|
| ១ អារម្ភកថា | ១ |
| ២ បណាមគាថា | ៥ |
| ៣ សាមណេរវិន័យបាឋ | ៧ |
| ៤ សិក្ខាបទ ១០ | ១០ |
| ៥ ទណ្ឌកម្ម ១០ | ១២ |
| ៦ នាសនង្គៈ ១០ | ១៣ |
| ៧ អង្គនៃសិក្ខាបទ ១០ | ១៤ |
| ៨ បយោគ | ២១ |
| ៩ កិច្ចនៃទណ្ឌកម្ម | ២២ |
| ១០ កិច្ចនៃនាសនង្គៈ | ២៧ |
| ១១ សេក្ខិយវត្ត | ៣៧ |
| ១២ សារូប ទី ១ មាន ២៦ | ៣៩ |
| ១៣ ភោជនប្បដិសំយុត្ត ទី ២ មាន ៣០ | ៤២ |
| ១៤ ធម្មទេសនាបដិសំយុត្ត ទី ៣ មាន ១៦ | ៤៧ |
| ១៥ បកិណ្ណកៈ ទី ៤ មាន ៣ | ៥១ |
| ១៦ បច្ចវេក្ខណៈ | ៥៣ |
| ១៧ ធាតុប្បច្ចវេក្ខណៈ | ៥៤ |
| ១៨ បដិកូលប្បច្ចវេក្ខណៈ | ៥៦ |
| ១៩ តង្ខណិកប្បច្ចវេក្ខណៈ | ៥៨ |
| ២០ អតីតប្បច្ចវេក្ខណៈ | ៦២ |


www.elibraryofcambodia.org

www.elibraryofcambodia.org

## អារម្ភកថា

ហេតុដែលបានកើតសៀវភៅសាមណេរវិន័យនេះឡើងនោះ កើតដោយលោកអ្នកឧកញ៉ាអធិបតីសេនា គេត មានបសាទស្សទ្ធា ប្រកបដោយកតញ្ញូកតវេទិតា ដល់គុណមាតាបិតា ហើយមានសេចក្ដីប្រារព្ធនឹងធ្វើបុណ្យ ឧទ្ទិសកុសលផល ជូនដល់បិតាដែលដល់នូវមរណភាព ទៅកាន់បរលោកហើយ ឃើញថាព្រះវិន័យជាអាយុព្រះពុទ្ធសាសនា បើព្រះវិន័យឋិតនៅ មានភិក្ខុសាមណេរសិក្សារៀនបេះដឹងប្រតិបត្តិដោយប្រពៃត្រឹមណា ព្រះពុទ្ធសាសនាក៏ឈ្មោះថាឋិតនៅត្រឹមណោះ ព្រះពុទ្ធសាសនាដែលនឹងរុងរឿងនោះ អាស្រ័យពីអ្នកសិក្សាប្រតិបត្តិដោយល្អ ។

លុះមានសេចក្ដីប្រារព្ធដូច្នេះហើយ ទើបបានអារាធនានិមន្តលោកគ្រូព្រះមហាវិមលធម្ម ថោង រៀនម្លូង ជាអធិបតី សាលាបាលីក្រុងភ្នំពេញ សុំឲ្យលោកជាត់ថែងរៀបរៀង

www.elibraryofcambodia.org

សាមណេរវិន័យនេះឲ្យ នឹងបានផ្ទួលពាងពុម្ពឲ្យបោះពុម្ព ឲ្យសម្រេចតាមប្រាថ្នា ដើម្បីជាហិតានុហិតប្រយោជន៍ ដល់អ្នកសិក្សាទាំងឡាយ, លោកក៏បានទទួលនិមន្តន៍ ហើយបានបាត់យើងខ្ញុំទាំងឡាយ គឺ ព្រះគ្រូសង្ឃសត្ថា ឈាត, ព្រះគ្រូសង្ឃវិជ្ជា តាត, ព្រះគ្រូវិមលបញ្ញា ស៊ូរ ឲ្យជាអ្នករៀបរៀងព្រះវិន័យនេះ ឲ្យបានសម្រេចឆ្លបសេចក្ដីប្រាថ្នា ។

www.elibraryofcambodia.org

យើងខ្ញុំទាំងឡាយ បានទទួលជាអ្នករៀបរៀងព្រះវិន័យនេះ តាមបាលី និងអដ្ឋកថា ដីកា គណ្ឋី ផ្ទបមានតាមគម្ពីរខាងក្រោមនេះ គឺ គម្ពីរមហាវគ្គ ១ តតិយសមន្តប្បាសាទិកាដ្ឋកថាមហាវគ្គ ១ តតិយសារត្ថទីបនីដីកាមហាវគ្គ ១ តតិយវិមតិវិនោទនីដីកាមហាវគ្គ ១ បាលិមុត្តកវិនយវិនិច្ឆ័យបុល្លគណ្ឋីមហាវគ្គ ១, តែមិនបានស្រង់យកបាលីសព្វគ្រប់មកតម្កល់ទុកក្នុងសៀវភៅនេះទេ ស្រង់យកមកខ្លះតែត្រង់បាលីដែលគួរទន្ទេញឲ្យចាំមាត់ ព្រោះឃើញថាវែងពេកណាស់

ក្រែងកុលបុត្រអ្នកសិក្សាថ្មី នឹងកើតធុញថប់រាយមាយ ក្នុងហេតុនេះ ទើបបានស្រង់យកតែសេចក្ដីបញ្ចេញមក ដើម្បីនឹងញុំាងកុលបុត្រឲ្យសិក្សាបានដោយងាយ ។

លុះរៀបរៀងស្រេចហើយ បានប្រគេនលោកគ្រូ ព្រះមហាវិមលធម្ម ឲ្យលោកពិនិត្យផ្ទៀងផ្ទាត់ឲ្យ, លោកក៏បានប្រជុំលោកអ្នកប្រាជ្ញ ដូចមានឈ្មោះនិងនាម ខាងក្រោមនេះគឺ ព្រះញាណបវរវិជ្ជា ឃែម វត្តបេក្ការាម ១, ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ១, ឧកញ៉ាភក្ដីរាជាបាឡាត់ ឃុំ ១, អ្នកអាចារ្យហ៊ត គ្រូបង្រៀនក្នុងសាលាបាលី ១ ឲ្យជួយផ្ទៀងផ្ទាត់ យល់ព្រមជាត្រឹមត្រូវប្រាកដហើយ ។

អ្នកឧកញ៉ាអធិបតីសេនាខ្ញុំ សូមឧទ្ទិសបំណែកផលបុណ្យ ដែលខ្ញុំបានសាងព្រះវិន័យនេះ និងផលបុណ្យដែលបានសាងសន្សំ ដោយបុញ្ញកិរិយាវត្ថុឯទៀត មានបរិវាទានជាដើម ជូនដល់បុព្វការីបុគ្គលទាំងអស់ មានបិតានៃខ្ញុំជាដើម

www.elibraryofcambodia.org

ដែលរំលាងខ្លួនទៅកាន់បរលោកនាយហើយ សូមឲ្យទទួលអនុមោទនាតាមសេចក្ដីប្រាថ្នាបុះ បើបានទទួលអនុមោទនាហើយ សូមផ្សាយសេចក្ដីសុខសួស្ដីដល់ខ្ញុំ ឲ្យបានសព្វទិវារាត្រី, ដោយអំណាចកុសលចេតនានិងសុច្ចរិតនេះ សូមសុខសួស្ដី ចូរចម្រើនដល់លោកអ្នកសក្យាទាំងឡាយ ឲ្យបានសព្វ ៗ កាលទៅហោង ៗ ៚

www.elibraryofcambodia.org

ពុទ្ធំ ធម្មញ្ច សង្ឃញ្ច ធមិត្វា រតនត្តយំ
យោបិ ទោ សាមណេរានំ សម្ពុទ្ធេនានុជានិតោ
ឥធេវ តំ បវក្ខាម សុខេនេវ បពោធិតុំ
ពុទ្ធាទិអានុភាវេន តេសញ្ច សោត្ថិ សព្វទា

យើងខ្ញុំទាំងឡាយ សូមនមស្ការនូវប្រជុំ ៣ នៃព្រះរតនៈ គឺ ពុទ្ធរតនៈ ១ ធម្មរតនៈ ១ សង្ឃរតនៈ ១ (ដោយកាយ វាចា ចិត្ត), វិន័យឯណា ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់អនុញ្ញាតទុកហើយ ដល់សាមណេរទាំងឡាយក្នុង ព្រះពុទ្ធសាសនា, យើងខ្ញុំទាំងឡាយ នឹងពោលនូវវិន័យនោះ ទុកក្នុងទីនេះ ដើម្បីនឹងញ៉ាំងសាមណេរ ជាអ្នកសិក្សាទាំង-ឡាយឲ្យដឹងដោយងាយ, ដោយអានុភាព នៃព្រះរតនត្រ័យ មានព្រះពុទ្ធរតនៈជាដើម សូមសិរីសួស្តីប្បវរចម្រើនដល់យើងខ្ញុំ ទាំងឡាយផង ដល់សាមណេរជាអ្នកសិក្សាទាំងឡាយផង សព្វៗកាលទៅហោង ។

www.elibraryofcambodia.org

## សាមណេរវិន័យ

កុលបុត្រ ដែលនឹងបួសជាសាមណេរ ត្រូវសិក្សាឲ្យចេះដឹងក្នុង **សាមណេរវិន័យ** ជាមុន គឺវិន័យដែលសាមណេរត្រូវសិក្សាតាមពុទ្ធានុញ្ញាតនិងពុទ្ធប្បញ្ញត្តិ, ឯវិន័យដែលសាមណេរត្រូវសិក្សានោះ មាន ៣០, បើបែកតាមឈ្មោះដើម មាន ៣ ពួក គឺ **សិក្ខាបទ** ១០ ជាពួក ១, **ទណ្ឌកម្ម** ១០ ជាពួក ១, **នាសនង្គ:** ១០ ជាពួក ១, រួមត្រូវជា ៣០ ។ បំណែកធម៌ដែលសាមណេរត្រូវសិក្សា ឈ្មោះថា **សិក្ខាបទ**, សេចក្ដីខុសដែលសាមណេរធ្វើឲ្យកន្លង ហើយភិក្ខុត្រូវធ្វើទោស មានឲ្យដងទឹកជាដើម ដើម្បីនឹងឲ្យរាងចាល ឈ្មោះថា **ទណ្ឌកម្ម**, អង្គដែលជាហេតុនឹងត្រូវឲ្យសាមណេរវិនាស គឺឲ្យសឹកចេញ ឈ្មោះថា **នាសនង្គ:** ។

ក៏ក្នុង **សាមណេរវិន័យ** នេះ នឹងពោល ឥវ **សាមណេរវិ-នយបាឋ** ដែលជាពុទ្ធានុញ្ញាតរៀបទុកជាមុន មិនបានប្រែបងជាប្រយោគទេ ព្រោះដើម្បីនឹងឲ្យស្រួលក្នុងការសិក្សា, តែថា

www.elibraryofcambodia.org

បានពោលអធិប្បាយក្នុងបាលីនោះ ជាសេចក្ដីសព្វគ្រប់ គឺ ពោលពី **សិក្ខាបទ**, **ទណ្ឌកម្ម** និង **នាសនង្គៈ** និង **វត្ត** មាន សេក្ខិយវត្តជាដើម ជាលំដាប់អំពី **សាមណេរវិនយបាឋ** នោះ តទៅ ៗ

www.elibraryofcambodia.org

## សាមណេរវិនយបាឋ

អនុជានាមិ ភិក្ខវេ សាមណេរានំ ទស សិក្ខាបទានិ តេសុ ច សាមណេរេហិ សិក្ខិតុំ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី អព្រហ្មចរិយា វេរមណី មុសាវាទា វេរមណី សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វិកាលភោជនា វេរមណី នច្ចគីតវាទិតវិសូកទស្សនា វេរមណី www.elibraryofcambodia.org មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី ឧច្ចាសយនមហាសយនា វេរមណី ជាតរូបរជតប្បដិគ្គហណា វេរមណី អនុជានាមិ ភិក្ខវេ សាមណេរានំ ឥមានិ ទស សិក្ខាបទានិ ឥមេសុ ច សាមណេរេហិ សិក្ខិតុន្តិ ។

អនុជានាមិ ភិក្ខវេ បញ្ចហង្គេហិ សមន្នាគតស្ស សាមណេរស្ស ទណ្ឌកម្មំ កាតុំ ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូនំ អនត្ថាយ បរិសក្កតិ

ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូ អក្កោសតិ បរិភាសតិ ភិក្ខូ ភិក្ខូហិ ភេទេតិ អនុជានាមិ ភិក្ខវេ ឥមេហិ បញ្ចហង្គេហិ សមន្នាគតស្ស សាមណេរស្ស ទណ្ឌកម្មំ កាតុន្តិ ។

អនុជានាមិ ភិក្ខវេ ទសហង្គេហិ សមន្នាគតំ សាមណេរំ នាសេតុំ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ អព្រហ្មចារី ហោតិ មុសា-វាទី ហោតិ មជ្ជបាយី ហោតិ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ មិច្ឆាទិដ្ឋិកោ ហោតិ ភិក្ខុនីទូស-កោ ហោតិ អនុជានាមិ ភិក្ខវេ ឥមេហិ ទស-ហង្គេហិ សមន្នាគតំ សាមណេរំ នាសេតុន្តិ ។

សេក្ខិយវត្តក្ខន្ធកវត្តេសុ អញ្ញេសុ ច សក្កីស្សជ្ជិ-អាទិលោកវជ្ជសិក្ខាបទេសុ ច សាមណេរេហិ វត្តិតព្វំ តត្ថ អវត្តមានោ អលជ្ជី ទណ្ឌកម្មារហោ វ ហោតិ ។

១ បាណាតិបាតា វេរមណី ចេតនាជាហេតុវៀរចាក ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២ អទិន្នាទានា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាកាន់យក នូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬ ដោយវាចា ។

៣ អព្រហ្មចរិយា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

www.elibraryofcambodia.org

៤ មុសាវាទា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

៥ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី ចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

៦ វិកាលភោជនា វេរមណី ចេតនាជាហេតុវៀរចាក កិរិយាបរិភោគ នូវភោជនាហារក្នុងកាលខុស ។

៧ នច្ចគីតវាទិតវិសូកទស្សនា វេរមណី បេតនាជាហេតុវៀរចាកកិរិយារាំនិងច្រៀងនិងប្រគំនិងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។

៨ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី បេតនាជាហេតុវៀរចាកកិរិយាទ្រទ្រង់ និងប្រដាប់ និងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេង ៗ ។

www.elibraryofcambodia.org

៩ ឧច្ចាសយនមហាសយនា វេរមណី បេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

១០ ជាតរូបរជតប្បដិគ្គហណា វេរមណី បេតនាជាហេតុវៀរចាកកិរិយាទទួលយក នូវមាសនិងប្រាក់ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរចំពោះមាសនិងប្រាក់នោះ ។

១ វិកាលភោជី ហោតិ សាមណេរ បរិភោគនូវភោជន៍អាហារក្នុងកាលខុស ។

២ នច្ចាទិវិសូកទស្សនោ ហោតិ សាមណេរ រាំនិងច្រៀងនិងប្រគំនិងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ ។

៣ មាលាទិធារណាទិកោ ហោតិ សាមណេរ ទ្រទ្រង់និងប្រដាប់គ្រឿងតាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេង ៗ ។

www.elibraryofcambodia.org

៤ ឧច្ចាសយនាទិកោ ហោតិ សាមណេរ ដេកឬអង្គុយលើទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

៥ ជាតរូបរជតប្បដិគ្គណ្ហកោ ហោតិ សាមណេរទទួលកាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯងឬប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរចំពោះមាសនិងប្រាក់នោះ ។

៦ ភិក្ខូនំ អវណ្ណភាសី ហោតិ សាមណេរ ព្យាយាមដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ ។

៧ ភិក្ខុនំ អនត្ថាយ បរិសក្កតិ សាមណេរ ព្យាយាម ដើម្បីមិនឲ្យជាប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។

៨ ភិក្ខូនំ អនាវាសាយ បរិសក្កតិ សាមណេរ ព្យាយាម ដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយ បាននូវទីលំនៅ ។

៩ ភិក្ខូ អក្កោសតិ បរិភាសតិ សាមណេរ ជេរប្រទេច នូវភិក្ខុទាំងឡាយ ។

១០ ភិក្ខូ ភិក្ខូហិ ភេទេតិ សាមណេរ ញុំាងភិក្ខុ ទាំងឡាយ ឲ្យបែកចាកភិក្ខុទាំងឡាយ ។

www.elibraryofcambodia.org

នាសនង្គៈ ១០

១ បាណាតិបាតី ហោតិ សាមណេរ ធ្វើសត្វមានជីវិត ឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

២ អទិន្នាទាយី ហោតិ សាមណេរ កាន់យកនូវវត្ថុដែល គេមិនបានឲ្យដោយកាយឬដោយវាចា ។

៣ អព្រហ្មចារី ហោតិ សាមណេរ ប្រព្រឹត្តនូវធម៌មិន ប្រសើរ គឺសេពនូវមេថុនធម្ម ។

៤ មុសាវាទី ហោតិ សាមណេរពោលនូវពាក្យកុហក ។

៥ មជ្ជបាយី ហោតិ សាមណេរ ផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ។

៦ ពុទ្ធស្ស អវណ្ណំ ភាសតិ សាមណេរ ពោលតិះដៀលនូវព្រះសម្មាសម្ពុទ្ធ ។

៧ ធម្មស្ស អវណ្ណំ ភាសតិ សាមណេរ ពោលតិះដៀលនូវព្រះធម៌ ។

www.elibraryofcambodia.org

៨ សង្ឃស្ស អវណ្ណំ ភាសតិ សាមណេរ ពោលតិះដៀលនូវព្រះសង្ឃ ។

៩ មិច្ឆាទិដ្ឋិកោ ហោតិ សាមណេរ មានទិដ្ឋិខុស ។

១០ ភិក្ខុនីទូសកោ ហោតិ សាមណេរ ប្រទូស្តនឹងនាងភិក្ខុនី ។

### អង្គនៃសិក្ខាបទ ១០

សាមណេរ កាលបើបានសិក្សាចាំស្ទាត់ ក្នុងសិក្ខាបទទាំង ១០ ហើយ ត្រូវសិក្សាឱ្យចាំប្តូលបំផុតស្ទាត់ ក្នុងអង្គនៃសិក្ខាបទទាំង ១០ តទៅទៀត ព្រោះសិក្ខាបទដែលនឹងបរិសុទ្ធ

ឬនឹងសៅហ្មង នឹងជាប់ធ្លាយនោះ លុះតែបានសិក្សាបាំអង្គ ឬលចិត្តស្អាត់ ទើបនឹងអាចវិនិច្ឆ័យ ពិចារណា កាត់សេចក្តី ដោយខ្លួនឯងថា សិក្ខាបទនោះៗ បរិសុទ្ធ ឬសៅហ្មង ដាច់ ធ្លាយនោះបាន ។

ឯអង្គនៃសិក្ខាបទ ១០ នោះ ដូចមានសេចក្តីតទៅនេះ

បាណាតិបាតៈ មានអង្គ ៥

១ បាណោ សត្វមានជីវិត

www.elibraryofcambodia.org

២ បាណសញ្ញិតា សេចក្តីដឹងថា សត្វមានជីវិត

៣ វធកចិត្តំ គំតនឹងសម្លាប់

៤ ឧបក្កមោ ព្យាយាមនឹងសម្លាប់

៥ តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

អទិន្នាទានៈ មានអង្គ ៥

១ បរបរិគ្គហិតំ ទ្រព្យដែលម្ចាស់របស់គេហួងហែងរក្សា

២ បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថា ទ្រព្យមានម្ចាស់ ហួងហែងរក្សា

៣ ថេយ្យចិត្តំ គិតនឹងលួច

៤ ឧបក្កមោ ព្យាយាមនឹងលួច

៥ តេន ហរណំ លួចបានដោយព្យាយាមនោះ ។

អព្រហ្មចរិយៈ មានអង្គ ៤

១ អេវនវត្ថុ វត្ថុជាទីទម្លាយនូវសីល គឺក្នុងទ្វារ

ទាំង ៣០ ទ្វារណាមួយ

២ សេវនចិត្តំ គិតនឹងសេព

www.elibraryofcambodia.org

៣ តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ

៤ មគ្គេន មគ្គប្បដិបាទនំ ញុំាងមគ្គនិងមគ្គឲ្យដល់គ្នា ។

មុសាវាទៈ មានអង្គ ៤

១ អតថំ វត្ថុ វត្ថុមិនពិត

២ វិសំវាទនចិត្តំ គិតនឹងពោលឲ្យខុស

៣ តជ្ជោ វាយាមោ ព្យាយាមនឹងពោលឲ្យខុសនោះ

៤ បរស្ស តទត្ថវិជាននំ ញុំាងអ្នកដទៃ ឲ្យដឹងច្បាស់

នូវសេចក្តីនោះ ។

សុរាមេរយៈ មានអង្គ ៤

១ មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្ដីស្រវឹង គឺសុរា និងមេរ័យ

២ បាតុកម្យតាចិត្តំ ចិត្តប្រាថ្នាដើម្បីនឹងផឹក

៣ តជ្ជោ វាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ

៤ តស្ស បានំ បានផឹកនូវទឹកស្រវឹងនោះ ឲ្យកន្លងបំពង់កចូលទៅ ។

www.elibraryofcambodia.org

វិកាលភោជនៈ មានអង្គ ៣

១ វិកាលោ កាលខុស គឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ

២ យាវិកាលិកំ របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើង ដរាបដល់ថ្ងៃត្រង់

៣ អជ្ឈោហរណំ បានលេបចូលទៅក្នុងបំពង់ក ។

នច្ចគីតៈ មានអង្គ ៣

១ នច្ចគីតាទិ ការល្បែងមានរាំនិងច្រៀងជាដើម

២ កត្តុកម្យតាបិត្តិ បំណងប្រាថ្នាដើម្បីនឹងធ្វើ

៣ សុតទស្សនត្តាយ គមនំ ទៅដើម្បីនឹងស្តាប់ឬមើល ហើយបានស្តាប់ឬមើល ។

មាលា មានអង្គ ៣

១ មាលាទិ វត្ថុសម្រាប់ប្រដាប់កាយមានផ្កាកម្រងជាដើម

២ ធារណេច្ឆតា សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង

៣ តស្ស ធារណំ បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់

www.elibraryofcambodia.org

ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

ឧច្ចាសយនៈ មានអង្គ ៣

១ ឧច្ចាសយនមហាសយនំ ទីដេក ទីអង្គុយ ដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ

២ បរិភោគចិត្តំ គិតនឹងដេកឬអង្គុយ

៣ បរិភោគករណំ បានដេកឬអង្គុយ ។

ជាតរូបៈ មានអង្គ ៣

១ ជាតរូបរជតំ មាសឬប្រាក់ដែលជាអកប្បិយភណ្ឌ

២ អត្តុទ្ទិសតា ចំពោះជារបស់ខ្លួន

៣ បដិគ្គណ្ហាទិ បានទទួលកាន់យកដោយខ្លួនឯង ឬ ប្រើគេឲ្យទទួលកាន់យកទុកដាក់ឲ្យ ហើយត្រេកអរចំពោះមាសឬប្រាក់នោះ ដោយឧបាយឯណានីមួយ ៗ

កាលបើសាមណេរប្រព្រឹត្តឲ្យកន្លង នូវសិក្ខាបទណាៗ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះៗ ទើបបានឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះ ក៏មិនបានឈ្មោះថាកន្លងនូវសិក្ខាបទនោះៗ ទេ ។

www.elibraryofcambodia.org

## **បយោគ**

សេចក្ដីព្យាយាមនឹងប្រព្រឹត្តធ្វើឲ្យកន្លងនូវសិក្ខាបទ ឈ្មោ

ថា **បយោគ** ។ នោះមាន ២ គឺ **សាហត្ថិកប្បយោគ** ១

**អាណត្តិកប្បយោគ** ១, ធ្វើឲ្យកន្លងដោយខ្លួនឯង ហៅថា

**សាហត្ថិកប្បយោគ** ប្រើអ្នកដទៃឲ្យធ្វើ ហៅថា **អាណត្តិ**

**កប្បយោគ** ។

ក្នុងសិក្ខាបទទាំង ១០ នោះ សិក្ខាបទទី ៣ គឺអព្រហ្មចរិ

យៈ, សិក្ខាបទទី ៤ គឺមុសាវាទៈ សិក្ខាបទទី ៥ គឺសុរាមេរយៈ

www.elibraryofcambodia.org

សិក្ខាបទទី ៦ គឺវិកាលភោជនៈ, សិក្ខាបទទី ៧ គឺនច្ចគីតៈ

សិក្ខាបទទី ៨ គឺមាលា និងសិក្ខាបទទី ៩ គឺឧច្ចាសយន

ទាំង ៧ សិក្ខាបទនេះ ជា **សាហត្ថិកប្បយោគ** ។

សិក្ខាបទទី ១ គឺបាណាតិបាតៈ, សិក្ខាបទទី ២ គឺអទិន្នា

ទានៈ និងសិក្ខាបទទី ១០ គឺជាតរូបៈ ទាំង ៣ សិក្ខាបទនេះ

ជា **អាណត្តិកប្បយោគ** ។

ម្យ៉ាងទៀត សិក្ខាបទទាំង ១០ នោះ លោកបែកចេញ

ជា ២ ពួក គឺ ជា **សាណត្តិកះ** ពួក ១, ជា **អនាណត្តិកះ** ពួក ១ ។

សិក្ខាបទឯណាដែលជា **អាណត្តិកប្បយោគ** សិក្ខាបទនោះជា **សាណត្តិកះ** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី ឈ្មោះថាកន្លង ដូចគ្នា ។

សិក្ខាបទឯណាដែលជា **សាហត្ថិកប្បយោគ** សិក្ខាបទនោះ ជា **អនាណត្តិកះ** ព្រោះអ្នករក្សាធ្វើដោយខ្លួនឯង ទើបឈ្មោះថាកន្លង បើប្រើអ្នកដទៃឲ្យធ្វើ នោះមិនបានឈ្មោះថាកន្លងទេ ។

www.elibraryofcambodia.org

## កិច្ចនៃទណ្ឌកម្ម

កិច្ចដែលនឹងធ្វើនូវទណ្ឌកម្មដល់សាមណេរនោះ គឺក្នុងទណ្ឌកម្មទាំង ១០ នោះ បើសាមណេរធ្វើឲ្យកន្លងដោយទណ្ឌកម្មឯណាមួយហើយ ត្រូវភិក្ខុជាឧបជ្ឈាយ៍ឬអាចារ្យ ធ្វើទោសដោយទណ្ឌកម្ម. ឯទណ្ឌកម្មនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អនុញ្ញាតឲ្យភិក្ខុធ្វើអាវរណកម្ម គឺហាមដល់សាមណេរទាំងឡាយដែលមានសេចក្ដីខុសគួរដល់ទណ្ឌកម្ម, ឯការដែលនឹងហាមនោះ គឺបើសាមណេរនោះនៅក្នុងទីណា តែងតែដើរចូលទៅក្នុងទីណា ត្រូវហាមកុំឲ្យនៅក្នុងទីនោះ កុំឲ្យដើរចូលទៅក្នុងទីនោះ, ឯទីដែលសាមណេរនៅនោះ គឺទីលំនៅដែលសាមណេរនៅជានិច្ចរបស់ខ្លួនក្ដី ទីដែលសាមណេរបានដោយលំដាប់វស្សាក្ដី ឈ្មោះថាជាលំនៅរបស់សាមណេរ, ទីដែលសាមណេរតែងដើរចូលទៅនោះ គឺទីបរិវេណឬទីលំនៅរបស់ឧបជ្ឈាយ៍ ឬអាចារ្យ ឈ្មោះថាទីដើរទៅនៃសាមណេរ ។

www.elibraryofcambodia.org

ឯកិច្ចដែលនឹងហាមនោះ ត្រូវហាមដោយពាក្យថា "អ្នកកុំនៅក្នុងទីនេះ, អ្នកកុំដើរចូលទៅក្នុងទីនោះ", ពាក្យហាមប៉ុណ្ណេះជាដើម ហៅថា អាវរណកម្ម ។

មួយទៀត ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តថា មិនឲ្យភិក្ខុហាមសាមណេរមិនឲ្យនៅក្នុងអាវាសទាំងមូល ឬហាមនូវមុខទ្វារ គឺបង្អត់មិនឲ្យសាមណេរបរិភោគអាហារ, បើភិក្ខុឯណាហាមមិនឲ្យនៅក្នុងអាវាសទាំងមូលក្តី ហាមនូវមុខទ្វារ ដោយពាក្យថា "អ្នកកុំបរិភោគអាហារ" ដូច្នេះ ឬយកបាត្រនិងចីវររបស់សាមណេរទៅទុកក្នុងកុដិ ដោយគិតថា "អញនឹងបង្អត់អាហារ" ដូច្នេះក្តី ភិក្ខុនោះត្រូវទុក្កដាបត្តិ, តែថាបើសាមណេរជាទុព្វចៈ គឺសាមណេរដែលរឹងរូស និងប្រដៅបានដោយក្រ ហើយជាអនាចារ ប្រព្រឹត្តកន្លងសិក្ខាបទផ្សេងៗនោះ, បើភិក្ខុនឹងធ្វើទណ្ឌកម្មដោយកិច្ចគឺយកយាគូ ឬភត្ត ឬបាត្រនិងចីវររបស់សាមណេរនោះ មកតម្កល់ទុកក្នុងទី១ ហើយបង្ហាញដោយពាក្យថា "កិច្ចទណ្ឌកម្មមានប្រមាណប៉ុណ្ណេះ បើអ្នកធ្វើរួចស្រេចហើយ អ្នកនឹងបាននូវរបស់ទាំងអស់នេះ" ដូច្នេះគួរ ។

www.elibraryofcambodia.org

ព្រះសម្មាសម្ពុទ្ធ ទ្រង់អនុញ្ញាតទណ្ឌកម្ម ដោយកិច្ចជា
អាវរណកម្ម គឺហាមមិនឲ្យសាមណេរនៅក្នុងទីដែលធ្លាប់នៅ
និងហាមមិនឲ្យចេញចូល ក្នុងទីដែលធ្លាប់ចេញចូលតែម្យ៉ាង
ប៉ុណ្ណោះ តែព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលដែលលើក
សង្គាយនានោះ លោកបង្គាប់ថា ឲ្យដាក់ទណ្ឌកម្មដោយកិច្ច
គឺឲ្យដងទឹក រកឧស ជញ្ជូនដីខ្សាច់ប្រើទតិបតាមទោសដែល
ធ្វើខុស, តែថា ដែលនឹងធ្វើដូច្នេះនោះ លុះតែឲ្យធ្វើដោយ
www.elibraryofcambodia.org
សេចក្តីករុណា ប្រាថ្នានឹងឲ្យវៀរចាកសេចក្តីខុសនោះ ទើប
គួរ, នឹងធ្វើដោយបាបចិត្ត គិតប្រាថ្នានឹងឲ្យសឹកចេញចាក
សាមណេរភេទនោះ មិនគួរទេ ។

ម្យ៉ាងទៀត នឹងឲ្យសាមណេរនោះដេកលើថ្មក្តៅ ឬ នឹង
យករបស់ធ្ងន់មានថ្មនិងឥដ្ឋជាដើម ដាក់សង្កត់ពីលើក្បាល ឬ
នឹងឲ្យបុះត្រាំទឹកឬមុជបុះទៅក្នុងទឹកនោះ ក៏មិនគួរទេ ។

ឯកិច្ចដែលនឹងធ្វើទណ្ឌកម្មនោះ ព្រះសម្មាសម្ពុទ្ធ ទ្រ
អនុញ្ញាតនិងបញ្ញត្តហាមថា ត្រូវព្រះឧបជ្ឈាយ៍ឬអាចារ្យធ្វើ, 

ភិក្ខុឯទៀតឃើញសាមណេរធ្វើខុស មិនបានប្រាប់ឧបជ្ឈាយ៍ ឬអាចារ្យរបស់សាមណេរនោះ ឱ្យដឹងជាមុន ហើយទៅធ្វើទណ្ឌកម្មដល់សាមណេរនោះ, ភិក្ខុអ្នកធ្វើ ត្រូវទុក្កដាបត្តិ, បើបានប្រាប់ដល់ឧបជ្ឈាយ៍ ឬអាចារ្យរបស់សាមណេរ ជាគម្រប់បីដងហើយ ឧបជ្ឈាយ៍ឬអាចារ្យ ក៏មិនធ្វើទណ្ឌកម្មដល់សាមណេរនោះ, ភិក្ខុនោះ នឹងធ្វើដោយខ្លួនឯង ក៏គួរ ។

ម្យ៉ាងទៀត បើឧបជ្ឈាយ៍ ឬអាចារ្យរបស់សាមណេរនោះ

www.elibraryofcambodia.org

បានអនុញ្ញាតគឺនិយាយផ្ដាំផ្ញើទុកថា បើសាមណេររបស់ខ្ញុំមានទោសខុស លោកប្រើធ្វើទណ្ឌកម្មឱ្យខ្ញុំផង, បើបានអនុញ្ញាតដូច្នេះហើយ មិនបាច់ប្រាប់ដល់ឧបជ្ឈាយ៍ឬអាចារ្យ ភិក្ខុនោះឃើញសាមណេរមានទោសខុសហើយ នឹងធ្វើទណ្ឌកម្មដោយខ្លួនឯងទៅក៏គួរ ។

បំណែកខាងសាមណេរវិញ បើត្រូវទោសគួរដល់ទណ្ឌកម្មហើយ គប្បីចូលទៅសូមទណ្ឌកម្មក្នុងសម្នាក់នៃព្រះឧបជ្ឈាយ៍ ឬអាចារ្យ ដោយពាក្យដូច្នេះ ៣ ដងថា

លគេយ្យាហំ គន្ថេ ឧណ្ណាគម្មំ អាយតឹ សំវរំ អាបជ្ជិស្សា
«បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាត្រូវបានឆ្លូវទណ្ឌក
ខ្ញុំព្រះករុណា នឹងដល់នូវសេចក្តីសង្រួម គឺថា នឹងប្រព្រឹត្តឲ្យ
តទៅខាងមុខទៀត» ។

លុះសូត្រសូមទណ្ឌកម្ម ដូច្នេះ ៣ ដង រួចហើយ ត្រ
ឧបជ្ឈាយ៍ឬអាចារ្យ ត្រូវដាក់ទណ្ឌកម្មឲ្យសាមណេរនោះ
តាមសមគួរដល់ទោសខុស ដូចន័យដែលបានពោលមកក្នុ
ខាងដើមហើយ, បើបានធ្វើទណ្ឌកម្មរួចហើយ សាម
ណេរនោះ ក៏ឈ្មោះថា បានតាំងនៅក្នុងសេចក្តីបរិសុទ្ធ ដូ
ប្រក្រតីអំពីដើម ។

កិច្ចនៃទណ្ឌកម្ម ចប់ ។

www.elibraryofcambodia.org

## កិច្ចនៃនាសនង្គៈ

កិច្ចដែលនឹងឲ្យសាមណេរវិនាសនោះ គឺក្នុង នាសនង្គៈ ទាំង ១០ នោះ បើសាមណេរធ្វើឲ្យកន្លងដោយនាសនង្គៈឯណាមួយហើយ ត្រូវព្រះឧបជ្ឈាយ៍ ឬអាចារ្យ ធ្វើឲ្យសាមណេរនោះវិនាស គឺឲ្យសឹកចេញ, តែថា កិច្ចដែលនឹងធ្វើនោះ មានវិធីខុសអំពីគ្នាខ្លះ ព្រោះក្នុងនាសនង្គៈទាំង ១០ នោះ លោកបែកចេញជាពួក គឺនាសនង្គៈ ៥ ខាងដើមដែលជាសិក្ខាបទ គឺតាំងពីសិក្ខាបទទី ១ ដល់សិក្ខាបទ ទី៥ ជាពួក ១, នាសនង្គៈ ៥ ខាងចុង គឺតាំងពីទី ៦ ដល់ទី ១០ ជាពួក ១ ។

បើសាមណេរឯណាប្រព្រឹត្តធ្វើឲ្យកន្លងនូវសិក្ខាបទ គឺនាសនង្គៈ ៥ ខាងដើម ក្នុងនាសនង្គៈឯណាមួយហើយ សរណគមន៍ក្តី សេចក្តីកាន់យកនូវព្រះឧបជ្ឈាយ៍ក្តី ទីលំនៅដែលខ្លួនធ្លាប់នៅនោះក្តី ក៏រម្ងាប់ គឺថាមិនមានសរណគមន៍ មិនមានព្រះឧបជ្ឈាយ៍ មិនមានទីលំនៅឡើយ, សង្ឃលាភដែលខ្លួនត្រូវបាននោះក្តី ក៏ដាច់ គឺថា មិនត្រូវបានឡើយ, សល់នៅតែទោសម្យ៉ាង

ព្រោះអាស្រ័យហេតុដែលស្លៀកដណ្តប់សំពត់កាសាវៈប៉ុណ្ណោះឯង, ព្រោះហេតុនោះ ព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវឲ្យសាមណេរនោះសឹកចេញ ក្នុងខណៈដែលប្រព្រឹត្តធ្វើឲ្យកន្លងសីលនោះ, បើសាមណេរនោះ ជាមនុស្សអាក្រក់ ប្រឡំពេញដោយទោសក្នុងសីលទាំង ៥ ខាងដើមនោះ ក្រៃពេកណាស់, ព្រះឧបជ្ឈាយ៍ ឬអាចារ្យ បានពោលប្រដៅគ្រប់ ៣ ដងហើយ នៅតែមិនស្តាប់ មិនមានសេចក្តីប្រាថ្នា នឹងតាំងនៅក្នុងសេចក្តីសង្រួមតទៅទៀតទេ នោះព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវអបលោកប្រាប់សង្ឃឲ្យដឹង ហើយឲ្យសឹកចេញ, បើសឹកចេញហើយមានប្រាថ្នានឹងបង់បួសវិញ បានចូលមកសូមផ្នួសទៀត ក៏គប្បីអបលោកប្រាប់សង្ឃឲ្យដឹង ហើយឲ្យបួសទៀតចុះ ។

ម្យ៉ាងទៀត បើសាមណេរឯណាធ្វើឲ្យកន្លងសិក្ខាបទណាមួយ ហើយដឹងទោសខ្លួនដោយ ១ រំពេចថា "អញធ្វើនេះខុសហើយ" ហើយមានចិត្តប្រាថ្នានឹងតាំងនៅក្នុងសេចក្តីសង្រួមតទៅទៀត, ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ កុំគប្បីឲ្យសាមណេរនោះ

www.elibraryofcambodia.org

សឹកឡើយ គប្បីឲ្យទទួលនូវព្រះត្រៃសរណគមន៍ និងកាន់យក
នូវព្រះឧបជ្ឈាយ៍ទៀតចុះ, ឯសិក្ខាបទទាំង ១០ នោះ ក៏សម្រេច
ព្រមដោយការទទួលយក នូវព្រះត្រៃសរណគមន៍នោះហើយ
ដូចជាចតុប្បារិសុទ្ធិសីលដែលសម្រេចដល់ភិក្ខុ ដោយញត្តិច-
តុត្ថកម្មវាចានោះដែរ. តែបើនិងសមាទានថ្មីទៀតក៏គួរ ដើម្បី
នឹងឲ្យមាំមួន និងបានជាទីគោរព និងសង្រួមទៅខាងមុខ, បើ
សាមណេរដែលទទួលយក នូវព្រះត្រៃសរណគមន៍ថ្មីទៀតនោះ

www.elibraryofcambodia.org

បានទទួលយកក្នុងថ្ងៃចូលបុរិមកវស្សា ហើយបានចូលបុរិមក-
វស្សាក្នុងថ្ងៃនោះ, សាមណេរនោះក៏ត្រូវបានសំពត់បំណាំវស្សា
ផង, បើបាននៅចាំវស្សាគ្រប់ ៣ ខែ ទាំងកាលចីវរ ដែលកើត
ដល់សង្ឃក្នុង ១ ខែ គឺតាំងពីថ្ងៃ ១ រោចខែអស្សុជ ដរាបដល់ថ្ងៃ
ពេញបូណ៌មីខែកត្តិកនោះ, សាមណេរនោះ ក៏ត្រូវបានស្មើភាគ
នឹងភិក្ខុដែរ, ម្យ៉ាងទៀត បើសាមណេរឯណាដែលបានចូលបុ-
រិមកវស្សាហើយ ត្រូវតាសនត្តៈក្នុងថ្ងៃមុនថ្ងៃចូលបច្ឆិមកវស្សា
គឺតាំងពីថ្ងៃ ២ រោចខែអាសាធ ដរាបដល់ថ្ងៃចូលបច្ឆិមកវស្សាគឺ

ថ្ងៃ ១ រោចខែស្រាពណ៍ក្នុងថ្ងៃណាមួយ ហើយបានទទួលយក
ព្រះត្រៃសរណគមន៍ និងកាន់យកព្រះឧបជ្ឈាយ៍ ហើយបាន
ចូលបច្ចុំមិកវស្សាទៀតក្តី សាមណេរដែលមិនបានចូលបុរិមិក-
វស្សា លុះដល់ថ្ងៃ ១ រោចខែស្រាពណ៍ទើបចូលបច្ចុំមិកវស្សាក្តី
ឬសាមណេរដែលមានវស្សាដាច់ក្តី កាលចីវរបរិភោគ គឺកិរិយា
បានប្រើប្រាស់នូវកាលចីវរ ក៏មិនបានសម្រេចដល់សាមណេរ
នោះៗទេ, ហេតុដូច្នោះ លាភដែលកើតឡើងដល់សង្ឃនោះ
www.elibraryofcambodia.org
សង្ឃ គប្បីធ្វើអបលោកនកម្ម ហើយចែកឲ្យដល់សាមណេរ
នោះៗបុះ, ឯវស្សាវាសិកលាភ គឺលាភដែលភិក្ខុ-សាមណេរ
នៅចាំវស្សាត្រូវបាននោះ បើទាយកជាម្ចាស់សេនាសនៈ គេ
បាននិយាយទុកមកអំពីមុន ដើម្បីនឹងគ្រប់គ្រងទីសេនាសនៈ
របស់គេថា " បើមានលោកម្ចាស់អង្គណា ចូលបច្ចុំមិកវស្សា
អាស្រ័យនៅក្នុងទីសេនាសនៈរបស់ខ្ញុំ នោះព្រះសង្ឃគប្បីឲ្យនូវ
វស្សាវាសិកលាភនេះ ដល់លោកម្ចាស់អង្គនោះផងចុះ" ដូច្នេះ
សង្ឃមិនបាច់ធ្វើអបលោកនកម្មទេ គប្បីឲ្យនូវវស្សាវាសិកលាភ

ដល់សាមណេរដែលបានបួលបញ្ចុំមិករិស្សា តាមពាក្យទាយក ជាម្ចាស់សេនាសនៈនោះ ៗ សាមណេរ មានទោសខុស ក្នុងនាសនង្គៈ៥ ខាងដើម ព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវធ្វើ ទោសដូចន័យដែលបានពោលមកហើយ ។

បើសាមណេរ មានទោសខុសក្នុងនាសនង្គៈ៥ ខាងចុង នោះ ត្រូវធ្វើទោសដោយកិច្ចប្លែកគ្នាអំពីនាសនង្គៈ ៥ ខាងដើម ១ៈ គឺថា បើសាមណេរឯណា ប្រព្រឹត្តឲ្យកន្លងក្នុងនាសនង្គៈ ទី៦-៧-៨នោះ ព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវសម្តែងទោស ប្រាប់សាមណេរនោះថា "ឯការពោលតិះដៀលព្រះរតនត្រ័យ នេះ មានទោសជាទម្ងន់ណាស់, អ្នកពោលតិះដៀលព្រះរតន- ត្រ័យដូច្នេះ មិនត្រូវទេ, ក្រោយ ៗ កុំពោលដូច្នេះទៀត", បើ បានពោលហាមប្រាម ដោយពាក្យមានដូច្នេះជាដើម ហើយ សាមណេរនោះលះបង់ទិដ្ឋិនោះបេញ ក៏គប្បីដាក់ទណ្ឌកម្មរប ហើយ ឲ្យសម្តែងទោសក្នុងកណ្តាលជំនុំសង្ឃដូច្នេះថា

www.elibraryofcambodia.org

អច្ចយោ មំ ភន្តេ អច្ចគមា យថាពលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ភន្តេ ឯវំ អភាសឹ តស្ស មេ អច្ចយំ អច្ចយតោ បដិគ្គណ្ហថ អាយតឹ សំវរេយ្យាមិ

បពិត្រលោកម្ចាស់ដ៏បម្រើន ទោសគឺសេចក្តីខុស ប្រព្រឹត្តកន្លងគ្របសង្កត់ហើយ នូវខ្ញុំព្រះករុណា ព្រោះជាមនុស្សពាលពេកណាស់ ជាមនុស្សវង្វេងពេកណាស់ ជាមនុស្សមិនឈ្លាសពេកណាស់, បពិត្រលោកម្ចាស់ដ៏បម្រើន ខ្ញុំព្រះករុណាឯណាបានពោលហើយ នូវពាក្យតិះដៀលព្រះរតនត្រ័យ យ៉ាងនេះ, សូមលោកម្ចាស់មេត្តាប្រោសអត់នូវទោសគឺសេចក្តីខុស ដល់ខ្ញុំព្រះករុណា ជាអ្នកមានទោសខុសនោះ, ខ្ញុំព្រះករុណា គប្បីសង្រួម គឺថា នឹងប្រព្រឹត្តឲ្យល្អ តទៅខាងមុខទៀត ។

លុះសម្តែងទោសដូច្នេះរួចហើយ ត្រូវឲ្យព្រះត្រៃសរណគមន៍ នឹងសីលថ្មីទៀត ព្រោះសាមណេរនោះជាបារាជិកហើយ បើបានហាមប្រាមដូច្នេះហើយ មិនលះបង់ទិដ្ឋិនោះចោលចេញទេ នោះព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវឲ្យសាមណេរនោះសឹកចេញ។

www.elibraryofcambodia.org

បើសាមណេរមានទោសខុសក្នុងនាសនង្គៈទី៩នោះ ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវសម្តែងទោស អំពីមិច្ឆាទិដ្ឋិ ប្រាប់សាមណេរនោះ ហើយហាមប្រាមឲ្យលះបង់ទិដ្ឋិនោះចេញ, បើសាមណេរនោះ លះបង់ទិដ្ឋិនោះចេញ ក៏គប្បីដាក់ទណ្ឌកម្មរួបហើយ ឲ្យសម្តែងទោសក្នុងកណ្តាលជំនុំសង្ឃថា

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ

យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ

www.elibraryofcambodia.org

ឯវំទិដ្ឋិកោ អហោសិំ តស្ស មេ អច្ចយំ

អច្ចយតោ បដិគ្គណ្ហថ អាយតិំ សំវរាយាតិ

បពិត្រលោកម្ចាស់ដ៏ចម្រើន ទោសគឺសេចក្តីខុសប្រព្រឹត្តកន្លងគ្របសង្កត់ហើយ នូវខ្ញុំព្រះករុណា ព្រោះជាមនុស្សពាលពេកណាស់ ជាមនុស្សវង្វេងពេកណាស់ ជាមនុស្សមិនឈ្លាសពេកណាស់, បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាឯណាជាមនុស្សឃើញខុសយ៉ាងនេះ សូមលោកម្ចាស់មេត្តាប្រោសអត់នូវទោសគឺសេចក្តីខុស ដល់ខ្ញុំព្រះករុណាជាអ្នកមានទោស

ខុសនោះ, ខ្ញុំព្រះករុណា គប្បីសង្រួម គឺថា នឹងប្រព្រឹត្តឲ្យល្អ តទៅខាងមុខទៀត ។ លុះសម្តែងទោសផ្លូវលោះរួចហើយ ត្រូវ ឲ្យព្រះត្រៃសរណគមន៍ និងសីលជាថ្មីទៀត, បើបានហាមប្រាម ផ្លូវលោះហើយ មិនលះបង់ទិដ្ឋិនោះចោលចេញទេ នោះព្រះ ឧបជ្ឈាយ ឬ អាចារ្យ ត្រូវផ្សឹកសាមណេរនោះចេញ ។

ម្យ៉ាងទៀត បើសាមណេរឯណា មិនបានកាន់យកនូវ ទិដ្ឋិផ្លូវលោះទេ គ្រាន់តែកាន់យកដោយវិបរិត ខុសបាកតុទូវបនា-

www.elibraryofcambodia.org

ធិប្បាយ, ភិក្ខុទាំងឡាយពោលទូន្មានហាម ក៏មិនលះបង់ នៅ តែពោលដោយវិបរិតខុសផ្លូវលោះដដែល, សាមណេរនោះឈ្មោះ ថាមិនដល់បារាជិកទេ, តែថា ព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវធ្វើ កណ្ដកនាសនៈ គឺឲ្យសាមណេរនោះសឹកចេញ ដូចជាកណ្ដក- សាមណេរ, បើមានប្រាថ្នានឹងតាំងនៅក្នុងសេចក្ដីសង្រួមតទៅ ទៀតនោះ ព្រះឧបជ្ឈាយ៍ ឬអាចារ្យ គប្បីអបលោកប្រាប់សង្ឃ ហើយបំបួសទៀតចុះ, បើមិនមានប្រាថ្នានឹងតាំងនៅក្នុងសេចក្ដី សង្រួមតទៅទៀតនោះ មិនត្រូវឲ្យបួសទៀតទេ ។

បើសាមណេរ មានទោសទសក្នុងនាសនង្គៈ ទី ១០ នោះ ត្រូវព្រះឧបជ្ឈាយ៍ឬអាចារ្យ ផ្សុកសាមណេរនោះចេញ បើទុកជាប្រាថ្នានឹងតាំងនៅ កង់សេចក្ដីសង្រួមតទៅទៀត ក៏មិនត្រូវឲ្យបំបួសទៀតទេ ព្រោះក្នុងនាសនង្គៈ ទី ១០ នេះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហាមផ្ដាច់ថា "មិនត្រូវឲ្យបំបួសទៀតឡើយ" ប៉ុន្តែ នាសនង្គៈទី១០នេះ ក្នុងកាលឥឡូវនេះ មិនមាន ព្រោះមិនមាននាងភិក្ខុនី ។

www.elibraryofcambodia.org

កិច្ចនៃនាសនង្គៈ ចប់ ។

ក្នុងកិច្ចនៃទណ្ឌកម្មនោះ សាមណេរត្រូវសិក្សាត្រង់សេចក្ដីដែលសូធ្យសូមទណ្ឌកម្ម ឲ្យចាំស្ទាត់ទាំងបាលីនិងសេចក្ដីប្រែជាសម្រាយ ។

ក្នុងកិច្ចនៃនាសនង្គៈនោះ ត្រូវសិក្សាត្រង់សេចក្ដីដែលសូធ្យសម្ដែងទោសឲ្យចាំស្ទាត់ទាំងបាលីនិងសេចក្ដីប្រែ, ឯកិច្ចក្រៅអំពីនោះ បើមិនអាចនឹងសិក្សាឲ្យចាំទាំងអស់បាន គ្រាន់

តែសិក្សាឲ្យដឹងជាសេចក្ដីទំនងៗក៏បាន ព្រោះជាកិច្ចរបស់ព្រ
ឧបជ្ឈាយាចារ្យទេ, តែបើ សាមណេរឯណា មានប្រាជ្ញាវ
វៃ ប្រកបដោយសេចក្ដីព្យាយាមមាំ អាចនឹងសិក្សាឲ្យចាំទាំ
អស់បាន, ប្ដូរឲ្យសាមណេរនោះសិក្សាចុះ ឈ្មោះថា ជាក
បម្រើនល្អណាស់ ។

សាមណេរវិន័យ ចប់ដោយសង្ខេប ។

---

www.elibraryofcambodia.org

## សេក្ខិយវត្ត

វត្ត ដែលសាមណេរគប្បីសិក្សា ឈ្មោះថា **សេក្ខិយវត្ត**ៗ នោះ ចាត់ជា ៤ ពួក, ពួកទី ១ ឈ្មោះ **សារូប** ពួកទី ២ ឈ្មោះ **គោចរទន្ធដិសំយុត្ត** ពួកទី ៣ ឈ្មោះ **ធម្មទេសនាបដិសំ-យុត្ត** ពួកទី ៤ ឈ្មោះ **បកិណ្ណកៈ** ។

### សារូប ទី ១ មាន ២៦

១- បរិមណ្ឌលនិវាសន សាមណេរគប្បីសិក្សាថា អញនឹងស្លៀកឲ្យជាបរិមណ្ឌល គឺខាងក្រោមគ្របក្បាលជង្គង់ចុះទៅ ៨ធ្នាប់, ខាងលើបិទមណ្ឌលផ្ចិត, ខាងមុខ-ក្រោយត្រឹមស្មើគ្នា។

២- បរិមណ្ឌលបារុបន សាមណេរគប្បីសិក្សាថា អញនឹងគ្រងចីពរឲ្យជាបរិមណ្ឌល គឺខាងក្រោមទើបឡើងលើស្បង់ ៤ធ្នាប់, ខាងលើបិទបាំងកែងដៃខាងឆ្វេង, ឲ្យរៀបរយ មិនឲ្យរយីករយាក ។

៣. សុប្បដិច្ឆន្នោ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងបិទបាំងរាងកាយឲ្យល្អដើរទៅក្នុងបនោះផ្ទះ។

www.elibraryofcambodia.org

៤- សុប្បដិច្ឆន្នោ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងបិទបាំងកាយឲ្យល្អ អង្គុយនៅក្នុងបន្លោះផ្ទះ ។

៥- សុសំវុតោ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងសង្រួមប្រយ័ត្នដោយល្អ គឺមិនបានរលាស់ដៃជើង ដើរទៅក្នុងបន្លោះផ្ទះ ។

៦- សុសំវុតោ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងសង្រួមប្រយ័ត្នដោយល្អ គឺមិនបានរលាស់ដៃ-ជើង អង្គុយនៅក្នុងបន្លោះផ្ទះ ។

www.elibraryofcambodia.org

៧- ឱក្ខិត្តចក្ខុ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងសម្លឹងខាងក្រោម គឺក្រឡេកមើលប្រមាណ ១ ជួរនឹម ដើរទៅក្នុងបន្លោះផ្ទះ ។

៨- ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងសម្លឹងខាងក្រោម គឺក្រឡេកមើលប្រមាណ ១ ជួរនឹម អង្គុយនៅក្នុងបន្លោះផ្ទះ ។

៩- ន ទុក្កដកាយ អន្តរាយរេ គមន សាមណេរគប្បី សិក្សាថា អញនឹងមិនស៊ើយបីវរណាត់កន្ទ្រើញ ដើរទៅក្នុង បន្លោះផ្ទះ ។

១០- ន ទុក្កដកាយ អន្តរាយរេ និសីទន- សាមណេរ គប្បីសិក្សាថា អញនឹងមិនស៊ើយបីវរណាត់កន្ទ្រើញ អង្គុយនៅ ក្នុងបន្លោះផ្ទះ ។

១១- ន ទុជ្ជគ្ឃិកាយ អន្តរាយរេ គមន សាមណេរ គប្បីសិក្សាថា អញនឹងមិនសើចខ្លាំង ដើរទៅក្នុងបន្លោះផ្ទះ ។

www.elibraryofcambodia.org

១២- ន ទុជ្ជគ្ឃិកាយ អន្តរាយរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងមិនសើចខ្លាំង អង្គុយនៅក្នុងបន្លោះផ្ទះ ។

១៣- អប្បសទ្ទោ អន្តរាយរេ គមន សាមណេរគប្បី សិក្សាថា អញនឹងនិយាយសំឡេងតិចៗដើរទៅក្នុងបន្លោះផ្ទះ។

១៤- អប្បសទ្ទោ អន្តរាយរេ និសីទន សាមណេរ គប្បីសិក្សាថា អញនឹងនិយាយសំឡេងតិចៗ អង្គុយនៅក្នុង បន្លោះផ្ទះ ។

១៥– ន កាយប្បចាលកំ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនគ្រវែងកាយ ដើរទៅក្នុងបន្លោះផ្ទះ ។

១៦– ន កាយប្បចាលកំ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនគ្រវែងកាយ អង្គុយនៅក្នុងបន្លោះផ្ទះ ។

១៧– ន ពាហប្បចាលកំ អន្តរឃរេ គមន-សាមណេរគប្បីសិក្សាថា អញនឹងមិនបង់ហោយ ដើរទៅក្នុងបន្លោះផ្ទះ ។

www.elibraryofcambodia.org

១៨– ន ពាហុប្បចាលកំ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនយោលដៃ អង្គុយនៅក្នុងបន្លោះផ្ទះ ។

១៩– ន សីសប្បចាលកំ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនអង្រួនក្បាល ដើរទៅក្នុងបន្លោះផ្ទះ ។

២០- ឥ សីសប្បបាលក់ អន្តរាយពេ និសីទន សាម-ណេរគប្បីសិក្សាថា អញនឹងមិនអង្រួនក្បាល អង្គុយនៅក្នុងបន្លោះផ្ទះ ។

២១- ឥ ខម្ភកតោ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនស្ទឹមបង្កេះ ដើរទៅក្នុងបន្លោះផ្ទះ ។

២២- ឥ ខម្ភកតោ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនស្ទឹមបង្កេះ អង្គុយនៅក្នុងបន្លោះផ្ទះ ។

www.elibraryofcambodia.org

២៣- ឥ ឧគុណ្ឋិតោ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនទទូរក្បាល ដើរទៅក្នុងបន្លោះផ្ទះ ។

២៤- ឥ ឧគុណ្ឋិតោ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនទទូរក្បាល អង្គុយនៅក្នុងបន្លោះផ្ទះ ។

២៥- ឥ ឧក្កុដិកាយ អន្តរឃរេ គមន សាមណេរគប្បីសិក្សាថា អញនឹងមិនបំពើតជើង ដើរទៅក្នុងបន្លោះផ្ទះ ។

២៦- ន បល្លត្ថិកាយ អន្តរឃរេ និសីទន សាមណេរគប្បីសិក្សាថា អញនឹងមិនត្របោមក្បាលជង្គង់ អង្គុយនៅក្នុងបន្ទោះផ្ទះ ។

សារុប បច់ ។

## គោចនប្បដិសំយុត្ត ទី ២ មាន ៣០

១- សក្កច្ចំ បិណ្ឌបាតប្បដិគ្គហណា សាមណេរគប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាត ដោយគោរព គឺមិនធ្វើអាការដូចជាបាកពោល ។

www.elibraryofcambodia.org

២- បត្តសញ្ញី បិណ្ឌបាតប្បដិគ្គហណា សាមណេរគប្បីសិក្សាថា អញនឹងសម្គាល់តែក្នុងបាត្រ ទទួលបិណ្ឌបាត គឺមិនបានក្រឡេកមើលទៅទីដទៃៗ ។

៣- សមសូបកបិណ្ឌបាតប្បដិគ្គហណា សាមណេរគប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតឲ្យមានសម្លស្មើគ្នា ។

៤- សមតិត្តិកបិណ្ឌបាតប្បដិគ្គហណា សាមណេរគប្បីសិក្សាថា អញនឹងទទួលបិណ្ឌបាតស្មើតែត្រឹមមាត់បាត្រ ។

៥- សក្កច្ចំ បិណ្ឌបាតភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ សាមណេរគប្បីសិក្សាថា អញនឹងបរិភោគបង្ហាន់បិណ្ឌបាត ដោយគោរព គឺមិនធ្វើអាការដូចជាមិនចង់បរិភោគ ។

៦- បត្តសញ្ញី បិណ្ឌបាតភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ សាមណេរគប្បីសិក្សាថា អញនឹងសម្គាល់តែក្នុងបាត្រ បរិភោគបង្ហាន់បិណ្ឌបាត គឺមិនបានក្រឡេកមើលទៅទីផងៃ ៗ ។

៧- សបទានបិណ្ឌបាតភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ សាមណេរគប្បីសិក្សាថា

www.elibraryofcambodia.org

អញនឹងបរិភោគបង្ហាន់បិណ្ឌបាតឲ្យស្មើ គឺមិនបានកកាយរងខ្វងកណ្ដាល ។

៨- សមសូបកបិណ្ឌបាតភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ សាមណេរគប្បីសិក្សាថា អញនឹងបរិភោគបង្ហាន់បិណ្ឌបាតមានសម្លស្មើគ្នា ។

៩- ន ថូបកតោ ឱមទ្ទិត្វា បិណ្ឌបាតភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ សាមណេរគប្បីសិក្សាថា អញនឹងមិនបានប្រមូលបុះអំពីកំពូលបាយ ហើយបរិភោគនូវបង្ហាន់បិណ្ឌបាត ។

១០- ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេ

សាមណេរគប្បីសិក្សាថា អញនឹងមិនកកាយបាយលុបសម្ល ឬ ម្ហូបក្រៀម ដើម្បីនឹងឲ្យទាយកគេឲ្យច្រើន ។

១១- ន សូបំ វា ព្យញ្ជនំ វា ឧត្តរិ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេន សាមណេរគប្បីសិក្សាថា អញមិនមានជំងឺ នឹងមិនសុំសម្ល ឬ ម្ហូបក្រៀម ឬ បាយ ដើម្បីខ្លួនហើយបរិភោគ ។

១២- ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឧលោកេន សាម-ណេរគប្បីសិក្សាថា អញនឹងមិនសម្គាល់គិតលើកទោស សម្លឹងមើលបាត្រសាមណេរដទៃ ។

www.elibraryofcambodia.org

១៣- នាតិមហន្តំ កវឡំ ករណោ សាមណេរ គប្បីសិក្សាថា អញនឹងមិនធ្វើពំនូតបាយឲ្យធំហួសប្រមាណ ។

១៤- ន កវឡាវច្ឆេទកំ ភុញ្ជេន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគទាំកាត់ពំនូតបាយមួយកំណាត់ម្តង ។

១៥- បរិមណ្ឌលអាលោបករណោ សាមណេរគប្បីសិក្សាថា អញនឹងធ្វើពំនូតបាយឲ្យជាបរិមណ្ឌល គឺឲ្យមូល ។

១៦- ន អនាហតេ ករវេឡ មុខទ្វារវិវរណំ សាមណេរ

គប្បីសិក្សាថា អញកាលបើពំនូតបាយមិនទាន់ដល់មាត់ នឹង

មិនហាមាត់ចាំ ។

១៧- ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបន

សាមណេរគប្បីសិក្សាថា អញកាលបើបរិភោគ នឹងមិនញាត់

ម្រាមដៃទាំងអស់ក្នុងមាត់ ។

១៨- ន សកវឡេន មុខេន ព្យាហរណំ សាមណេរ

គប្បីសិក្សាថា អញនឹងមិននិយាយទាំងភោជនក្នុងមាត់ ។

www.elibraryofcambodia.org

១៩- ន បិណ្ឌុក្ខេបកំ ភុញ្ជន សាមណេរគប្បីសិក្សាថា

អញនឹងមិនបរិភោគបោះដុំបាយ ដុំត្រី ដុំសាច់ជាដើម ចូល

ក្នុងមាត់ ។

២០- ន អវគណ្ឌការកំ ភុញ្ជន សាមណេរគប្បីសិក្សា

ថា អញនឹងមិនបរិភោគបៀមពំនូតបាយ ឲ្យទុលថ្ពាល់ឡើង

ដូចជាស្វា ។

២១- ន ហត្ថនិទ្ធុនកំ ភុញ្ជន សាមណេរគប្បីសិក្សាថា

អញនឹងមិនបរិភោគរលាស់ដៃបណ្ដើរ ។

២២– ន សិត្ថាវការកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគឲ្យរោយរាយគ្រាប់បាយ ។

២៣– ន ជិវ្ហានិច្ឆារកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលៀនអណ្តាតបេញមកខាងក្រៅ ។

២៤– ន ចបុចបុការកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគឲ្យឮផ្ចប់ៗ ។

២៥– ន សុរុសុរុការកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគហុតទឹកសម្លជាដើមឲ្យឮគ្រូកៗ ។

www.elibraryofcambodia.org

២៦– ន ហត្ថនិល្លេហកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទដៃ ។

២៧– ន បត្តនិល្លេហកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទបាត្រ ។

២៨– ន ឱដ្ឋនិល្លេហកភុញ្ជន សាមណេរគប្បីសិក្សាថា អញនឹងមិនបរិភោគលិទបបូរមាត់ ។

២៩- ន សាមំសេន ហេត្ថុន បានឹយហាលកប្បជំគ្គហណ សាមណេរគប្បីសិក្សាថា អញនឹងមិនទទួលភាជនៈទឹកដោយដៃប្រឡាក់អាមិស ។

៣០ ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេន សាមណេរគប្បីសិក្សាថា អញនឹងមិនចាក់ទឹកដែលលាងបាត្រក្នុងបន្លោះផ្ទះទាំងគ្រាប់បាយ ។

( ភាជនប្បដិសំយុត្ត ចប់ ។

www.elibraryofcambodia.org

ធម្មទេសនាបដិសំយុត្ត ទី ៣ មាន១៦

១- ន ឆត្តបាណិស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានឆត្រក្នុងដៃ ។

២- ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជំងឺ មានឈើច្រត់ក្នុងដៃ ។

៣- ន សត្ថបាណិស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ មានគ្រឿងសស្ត្រាក្នុងដៃ ។

៤- ន អាវុធបាណិស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ មានអាវុធក្នុងដៃ ។

៥- ន បាទុការូឡ្ហស្ស អគិលានស្ស ធម្មទេសន

www.elibraryofcambodia.org

សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ ពាក់ទ្រនាប់ជើងឈើ ឬ ទ្រនាប់ជើងស្មៅជាដើម ។

៦- ន ឧបាហនារូឡ្ហស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ ពាក់ស្បែកជើង ។

៧- ន យានគតស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្តែងធម៌ដល់មនុស្ស គ្មានជំងឺ នៅលើយាន មានរថជាដើម ។

៨- ន សយនគតស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ នៅលើទីដំណេក ។

៩- ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ អង្គុយត្រពោមក្បាលជង្គង់ ។

១០- ន វេឋិតសីសស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ ជួតឈ្នួតក្បាល ។

www.elibraryofcambodia.org

១១- ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹងមិនសម្ដែងធម៌ដល់មនុស្ស គ្មានជំងឺ ទទូរក្បាល ។

១២ ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មទេសន សាមណេរគប្បីសិក្សាថា អញនឹង មិនអង្គុយលើផែនដី សម្ដែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើទីអាសនៈ មានកន្ទេលជាដើម ។

១៣- ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំទេសេន្ត សាមណេរគប្បីសិក្សាថា អញនឹងមិនអង្គុយលើទីអាសនៈទាប សម្តែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើទីអាសនៈខ្ពស់ ។

១៤- ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំទេសេន្ត សាមណេរគប្បីសិក្សាថា អញនឹងមិនឈរ សម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដែលអង្គុយ ។

www.elibraryofcambodia.org

១៥- ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំទេសេន្ត សាមណេរគប្បីសិក្សាថា អញនឹងមិនដើរអំពីខាងក្រោយ សម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដើរអំពីខាងមុខ ។

១៦- ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំទេសេន្ត សាមណេរគប្បីសិក្សាថា អញនឹងមិនដើរក្រៅផ្លូវ សម្តែងធម៌ដល់មនុស្សគ្មានជំងឺ ដើរក្នុងផ្លូវ ។

ធម្មទេសនាបដិសំយុត្ត ចប់ ។

**បរិច្ឆេទ ទី ៤ មាន ៣**

១- ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករណា សាមណេរគប្បីសិក្សាថា អញគ្មានជំងឺ នឹងមិនឈរបន្ទោឧច្ចារៈ ឬ បស្សាវៈ ។

២- ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណា សាមណេរគប្បីសិក្សាថា អញគ្មានជំងឺ នឹងមិនបន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ លើភួតគ្គាម គឺដើមឈើ ឬ តម្ពស្មៅ ។

www.elibraryofcambodia.org

៣- ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករណា សាមណេរគប្បីសិក្សាថា អញគ្មានជំងឺ នឹងមិនបន្ទោឧច្ចារៈ បស្សាវៈ ឬ ស្តោះទឹកមាត់ ដាក់លើទឹកដែលមិនគួរធ្វើជួប្រេះបាន ។

បរិច្ឆេទចប់ ។

**សេខិយធម្ម** ទាំង ៧៥ នេះ កុលបុត្រដែលបានបព្វជ្ជាជាសាមណេររួបហើយ ត្រូវសិក្សាជាលំដាប់អំពី **សាមណេរ-**

វិន័យ មក, ឯ វត្ត ដែលសាមណេរត្រូវសិក្សានោះ នឹងបាន មានតែ សេខិយវត្ត ប៉ុណ្ណោះក៏ទេ, វត្ត ដទៃទៀតដែលព្រះ សម្មាសម្ពុទ្ធទ្រង់បញ្ញត្តនិងអនុញ្ញាតទុក ក្នុងខន្ធកវិន័យនោះក្តី សិក្ខាបទដែលជាលោកវជ្ជៈ មានសុរាវិសជ្ជនិសិក្ខាបទជាដើម នោះក្តី សាមណេរក៏ត្រូវសិក្សាឲ្យបានដឹង ហើយត្រូវប្រព្រឹត្ត តាមដូចជាភិក្ខុដែរ, បើសាមណេរឯណា មិនប្រព្រឹត្តតាម សាមណេរនោះ ឈ្មោះថា អលជ្ជី, ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ត្រូវធ្វើទណ្ឌកម្មដល់សាមណេរនោះ តាមសមគួរដល់ទោស ដែលប្រព្រឹត្តធ្វើឲ្យកន្លង ។

សេខិយវត្ត ចប់ ។

www.elibraryofcambodia.org

**បច្ចវេក្ខណៈ**

កុលបុត្រ ដែលបួសក្នុងព្រះពុទ្ធសាសនា ត្រូវសិក្សាក្នុង **បច្ចវេក្ខណៈ** គឺលក្ខណៈ សម្រាប់ពិចារណានូវបច្ច័យដែលខ្លួនត្រូវអាស្រ័យ ឱ្យចេះចាំស្ទាត់ទាំងបាលីនិងសេចក្ដីប្រែជាសម្រាយ, ឯបច្ច័យដែលបព្វជិតត្រូវអាស្រ័យនោះ មាន ៤ គឺ **ចីវរប្បច្ច័យ** សំពត់ដែលបព្វជិតគួរស្លៀកដណ្ដប់ប្រើប្រាស់បាន មានត្រៃចីវរជាដើម ១, **បិណ្ឌបាតប្បច្ច័យ** ភោជនាហារដែលបព្វជិតត្រូវបរិភោគបាន តាំងអំពីវេលាអរុណរះឡើងដរាបដល់ថ្ងៃត្រង់ មានបាយជាដើម ១, **សេនាសនប្បច្ច័យ** ទីសេនាសនៈដែលបព្វជិតត្រូវអាស្រ័យប្រើប្រាស់បាន មានកុដិសាលាជាដើម ១, **គិលានប្បច្ច័យ** ថ្នាំសម្រាប់មនុស្សមានជំងឺដែលបព្វជិតត្រូវបរិភោគប្រើប្រាស់បាន មានសប្បិជាដើម១ ។

ក្នុងបច្ច័យមួយ ៗ នោះ ពោលដោយ **បច្ចវេក្ខណៈ** គឺ លក្ខណៈសម្រាបពិចារណា មានបួន ៗ គឺ **ធាតុប្បច្ចវេក្ខណៈ** ១, **បដិក្កូលប្បច្ចវេក្ខណៈ** ១, **តង្ខណិកប្បច្ចវេក្ខណៈ** ១, **អតីតប្បច្ចវេក្ខណៈ** ១ ។

www.elibraryofcambodia.org

## ធាតុប្បច្ចវេក្ខណៈ

ធាតុប្បច្ចវេក្ខណៈនោះ គឺឲ្យពិចារណា ក្នុងកាលដែលទទួលនូវបច្ច័យ ៤ ឲ្យឃើញថាជា ធាតុ ។

កាលដែលទទួល នូវ ចីវរប្បច្ច័យ ឲ្យពិចារណាដូច្នេះថា

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ

យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ

ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

សំពត់ចីវរឯណោះ ឬសំពត់ចីវរនេះ គ្រាន់តែជាធាតុពិតប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវ បិណ្ឌបាតប្បច្ច័យ ឲ្យពិចារណាដូច្នេះថា

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ

បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ

ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

www.elibraryofcambodia.org

បង្ហាន់បិណ្ឌបាតឯណានេះ បង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គលគឺអាត្មាដែលជាអ្នកបរិភោគបង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួល នូវ សេនាសនបច្ច័យ ត្រូវពិចារណាដូច្នេះថា

www.elibraryofcambodia.org

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ
សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ
ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគប្រើប្រាស់ទីសេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

កាលដែលទទួល នូវ គិលានប្បច្ច័យ ឲ្យពិចារណាដូច្នេះថា

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ ។

www.elibraryofcambodia.org

### បដិកូលបច្ចវេក្ខណៈ

បដិកូលប្បច្ចវេក្ខណៈនោះ គឺឲ្យពិចារណា ក្នុងខណៈដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ ៤ ឲ្យឃើញថាជារបស់បដិ-កូលគួរខ្ពើមរអើម ។

កាលដែលប្រារព្ធនឹងប្រើប្រាស់ នូវ ចីវរប្បច្ច័យ ឲ្យពិចារ-ណាដូច្នេះថា

សញ្ញាតិ បត្តមានំ បីវរានិ អជ្ឈត្តនិយានិ ធម៌

បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។

សំពត់ប៉ីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើម

ឡើយ លុះពាល់ត្រូវនឹងកាយស្អុយនេះកាលណាហើយ ក៏

កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់ នូវ **បិណ្ឌបាត-**

**បច្ចយ័** ឲ្យពិចារណាដូច្នេះថា

សព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ធម៌

បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

បង្ហាន់បិណ្ឌបាតទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើម

ឡើយ លុះពាល់ត្រូវនឹងកាយស្អុយនេះកាលណាហើយ ក៏

កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់ នូវ **សេនាស-**

**នបច្ចយ័** ឲ្យពិចារណាដូច្នេះថា

សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនីយានិ

ធម៌ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។

www.elibraryofcambodia.org

ទីសេនាសនៈទាំងឡាយ ទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវគល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

កាលដែលប្រារព្ធនឹងបរិភោគ នូវ **គិលានប្បច្ច័យ** ឲ្យពិចារណាដូច្នេះថា

សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជ-

បរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ

បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

www.elibraryofcambodia.org

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក ។

**តង្ខណិកប្បច្ចវេក្ខណៈ**

តង្ខណិកប្បច្ចវេក្ខណៈនោះ គឺឲ្យពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យ ៤ ។

កាលដែលប្រើប្រាស់នូវ **ចីវរប្បច្ច័យ** ឲ្យពិចារណាដូច្នេះថា

បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវ-

ទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃា

តាយ ឌំសមកសវាតាតបសិរឹសប[១] សម្ផស្សានំ

បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។

បព្វជិតគប្បីពិចារណា ដោយឧបាយថា អាត្មាអាស្រ័យ

សេព គឺប្រើប្រាស់នូវសំពត់ចីវរ កំណត់ទុក ដើម្បីនឹងការពារ

នូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវ

សម្ផស្ស រមោម មូស ខ្យល់ កម្តៅថ្ងៃ នឹងពស់តូច ពស់ធំ

ទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំងនូវអវយវៈដែលធ្វើ

នូវសេចក្តីខ្មាស់អៀនឲ្យកម្រើក ។

www.elibraryofcambodia.org

កាលដែលបរិភោគនូវមិណ្ឌបាតប្បច្ច័យ ឲ្យពិចារណាដូច្នេះថា

បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ

ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូស-

នាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា

យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គ-

---

១ សិរិសប្ប នតិបិ សំយោគោ ករគោ បោតិ ។

ហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ
នវញ្ច វេទនំ ឧប្បាទេស្សាមិ យាត្រា ច
មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឲ្យកើតបុរិសមានៈស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបរីក៏ទេ ដើម្បីនឹងធ្វើឲ្យផូរផង់ល្អ ដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយៈ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោសៈ មានមិនប្រអួសកាយ មិនប្រអួសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគ

នូវបង្ហាន់បិណ្ឌបាតនេះ ។

កាលដែលបរិភោគប្រើប្រាស់ នូវ **សេនាសនប្បច្ច័យ** ឲ្យពិចារណាដូច្នេះថា

បដិសង្ខា យោនិសោ សេនាសនំ បដិ-
សេវាមិ យាវទេវ សីតស្ស បដិឃាតាយ
ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតប-
សិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ
ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ(១) ។

www.elibraryofcambodia.org

បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេពគឹបរិភោគប្រើប្រាស់នូវទីសេនាសនៈ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្ដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលដែលបរិភោគនូវ **គិលានប្បច្ច័យ** ឲ្យពិចារណាដូច្នេះថា

---

១សព្វបោតកេសុ ឦទិសោយេវ បាឋោ ទិស្សតិ ។

បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ

បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ

វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។

បព្វជិតគប្បីពិចារណា ដោយឧបាយថា អញអាស្រ័យ សេពគឺបរិភោគ នូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិតគឺថ្នាំជាបច្ច័យ ដល់អ្នកជំងឺ កំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេង ៗ ដែលកើតឡើងហើយ ដើម្បីប្រាស

www.elibraryofcambodia.org

ចាកទុក្ខទាំងជាធម្មតា ។

**អតីតបច្ចវេក្ខណៈ**

អតីតបច្ចវេក្ខណៈនោះ គឺឲ្យពិចារណានូវបច្ច័យ ៤ ក្នុង អតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណា បានតែក្នុងថ្ងៃនោះ គឺក្នុងវេលាយប់ ១ ថ្ងៃ ១ កុំឲ្យអរុណរះ ឡើងមាន, ក្នុងបច្ចវេក្ខណៈ មួយ ៗ ពិចារណា ១ ចប់ ឬ ២ ចប់, ៣ ចប់ ក៏បាន ។

កាលដែលនឹងពិចារណានូវចីវរបច្ច័យ ឲ្យពិចារណាដូច្នេះថា

អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ-ឃាតាយ ឌំសមកសវាតាតបសិរិសប សម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ ។

សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវក្ដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្ដៅថ្ងៃ នឹងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្ដីអៀនខ្មាសឲ្យកម្រើក ។

www.elibraryofcambodia.org

កាលដែលនឹងពិចារណា នូវ បិណ្ឌបាតប្បច្ច័យឲ្យពិចារណាដូច្នេះថា

អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិ-ភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសូបរតិយា ព្រហ្មចរិយា-

នុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ

នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ

ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

បង្ហាន់បិណ្ឌបាតឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ បង្ហាន់បិណ្ឌបាតនោះ អញបរិភោគ ដើម្បីនឹងលេង ដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឲ្យកើតមុរិស-មានះស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែង រាងកាយ ដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឲ្យធូរធង់សម្បុរ ដូច

www.elibraryofcambodia.org

អ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឲ្យតាំងនៅ នៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បី នឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្ម-ចរិយៈ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែល មានហើយផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិន ឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ គឺ សេចក្តីមិនមានទោស មានមិនប្រអូសកាយ មិនប្រអូសចិត្ត ជាដើមក៏ កិរិយានៅសប្បាយក្នុងឥរិយាបថ ទាំង ៤ ក្តី នឹងមាន

ដល់អញ ដោយបានបរិភោគនូវបង្ហាន់បិណ្ឌបាតនេះ ។

កាលដែលនឹងពិចារណានូវ **សេនាសនបច្ច័យ** ឲ្យពិចារណាដូច្នេះថា

អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ សេនាសនំ
បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ
ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតា-
តបសិរិសប សម្ផស្សានំ បដិឃាតាយ យាវ-
ទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។

www.elibraryofcambodia.org

ទីសេនាសនៈឯណា ដែលអញមិនបានពិចារណាហើយ បរិភោគប្រើប្រាស់ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលដែលនឹងពិចារណា នូវ **គិលានបច្ច័យ** ឲ្យពិចារណា

ដូច្នេះថា

អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ គិលា-

នប្បច្ចយភេសជ្ជបរិក្ខារោ បរិភុត្តោ សោ

យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទ-

នានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេង ៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខទាំងជាធម្មតា ។

បើកាលដែលទទួល និងកាលដែលប្រារព្ធដើម្បីបរិភោគ និងកាលដែលបរិភោគនោះ បានពិចារណាដោយ **ធាតុប្បច្ចវេក្ខណៈ** ដោយ **បដិកូលប្បច្ចវេក្ខណៈ** ដោយ **តង្ខណិកប្បច្ចវេក្ខណៈ** រួចសព្វគ្រប់ហើយ នឹងមិនបាច់ពិចារណាក្នុង **អតីតប្បច្ចវេក្ខណៈ** ទៀត ក៏បាន ។ ៚

បច្ចវេក្ខណៈ ចប់ ។

www.elibraryofcambodia.org

www.elibraryofcambodia.org

www.elibraryofcambodia.org

9947
3/3

www.elibraryofcambodia.org

www.elibraryofcambodia.org

www.elibraryofcambodia.org